ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ ពុធ ១៣ រោច ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃ ២៨ ខែ សីហា ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មាន
## កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ) ស្តីពីវិធានការដោះស្រាយបញ្ហាហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តព្រះសីហនុ

នាព្រឹកថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (គ.ស.ហ) ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន **គ.ស.ហ** មានរៀបចំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាអំពី **"វិធានការដោះស្រាយបញ្ហាហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តព្រះសីហនុ"** ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមរដ្ឋមន្ត្រី និងដឹកនាំជាន់ខ្ពស់នៃក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។

ស្របពេលនឹងកំណើនយ៉ាងគំហុកនៃការអភិវឌ្ឍ រួមនឹងកំណើនប្រជាជនខ្ពស់ក្នុងក្រុងព្រះសីហនុ, លទ្ធភាពទ្រទ្រង់នៃហេដ្ឋាចនាសម្ព័ន្ធបរិវេណរបស់ខេត្តត្រូវបាន និងកំពុងក្លាយជាបញ្ហាប្រឈមដ៏ធំសម្រាប់ខេត្តភាគនិរតីមួយនេះ ។ ជាក់ស្តែង, ក្រៅពីបញ្ហាគុណភាព និងសមត្ថភាពទ្រទ្រង់, ផ្លូវថ្នល់ក្នុងក្រុងក៏ទទួលរកការខូចខាតគួរឱ្យកត់សម្គាល់ដោយសារជំនន់ទឹកភ្លៀងនាពេលថ្មីៗនេះ ជាមួយនឹងការរំលោភចាក់បំពេញដីដោយខុសច្បាប់លើអូរធម្មជាតិដែលជាប្រព័ន្ធរំដោះទឹកភ្លៀងចាក់ចូលសមុទ្រ ។ បន្ថែមលើនេះ, ប្រព័ន្ធលូរំដោះទឹកភ្លៀង និងទឹកកខ្វក់បច្ចុប្បន្នក៏មិនអាចឆ្លើយតបដោយប្រសិទ្ធិភាពទៅនឹងទំហំជំនន់ទឹកភ្លៀង និងការបញ្ចេញទឹកកខ្វក់ពីក្នុងក្រុងទាំងមូលនោះទេ ។ នៅឆ្នាំ ២០១៨ បរិមាណបញ្ចេញទឹកកខ្វក់នៅខេត្តព្រះសីហនុ មានរហូតដល់ ២៥.០០០ ម៉ែត្រគូប ក្នុង ១ ថ្ងៃ ហើយត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់ ៤៧.០០០ ម៉ែត្រគូប ក្នុង ១ ថ្ងៃ នៅឆ្នាំ ២០២៣ និងអាចបន្តកើនឡើងរហូតដល់ ៦៤.០០០ ម៉ែត្រគូប ក្នុង ១ ថ្ងៃ នៅឆ្នាំ ២០៣០ ។ បញ្ហាប្រឈមទាំងនេះ ទាមទារឱ្យមានវិធានការដោះស្រាយប្រកបដោយប្រសិទ្ធភាព និងបន្ទាន់ដើម្បីកែលម្អប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តព្រះសីហនុ ។

ក្នុងន័យនេះ, រាជរដ្ឋាភិបាល និងអាជ្ញាធរដែនដីបានខិតខំជួសជុលកែលំអរផ្លូវក្នុងក្រុងជាបន្តបន្ទាប់ ដោយគម្រោងជួសជុលផ្លូវចំនួន ២២ ខ្សែ ក្នុងក្រុង ស្មើនឹងប្រវែង ៣៦.៤៣៥ ម៉ែត្រ បានទទួលការអនុម័តរួចហើយ ។ មកទល់ពេលនេះ, ការស្តារ និងជួសជុលផ្លូវទាំងនោះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ជាពិសេសកំណាត់ផ្លូវប្រើប្រាស់ចរិកាថ្នាក់ក្រោមជាតិ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ មានកំណាត់ផ្លូវមួយចំនួនហាក់មានវឌ្ឍភាពយឺត ដោយជួបប្រទះការលំបាកមួយចំនួន រួមមាន ការទទួលរងជំនន់ទឹកភ្លៀងបណ្តាលឱ្យមានការលិចលង់លើកំណាត់ផ្លូវមួយចំនួនជាដើម ដែលទាមទារឱ្យមានការខិតខំជំនះបន្ថែមទៀត ។ ជាមួយគ្នានេះ, ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធរំដោះទឹកភ្លៀង និងទឹកកខ្វក់ក្នុងក្រុង ដែលធ្វើឱ្យក្រុងទទួលរងនូវការលិចលង់ពេលមានភ្លៀងធ្លាក់ខ្លាំងប៉ុន្មានថ្ងៃកន្លងមកនេះ ។

ជាមួយនឹងការគិតគូរ និងវិធានការអនុវត្តរយៈពេលវែងក្នុងការរៀបចំប្រព័ន្ធរំដោះទឹកក្នុងក្រុង, ស្ថានការបច្ចុប្បន្នតម្រូវឱ្យមានការគិតគូរលើវិធានការបន្ទាន់ ដើម្បីបញ្ចៀសការលិចលង់ក្រុងកម្រិតធ្ងន់ធ្ងរបន្តទៀត ជាពិសេស ចំណាត់ការបន្ទាន់ជាក់ស្តែង ចំពោះការរំលោភបំពានលើនិយាមការអូរធម្មជាតិទាំង ៥ ក្នុងក្រុង ។ ឆ្លើយបតនឹងបញ្ហានេះ, អង្គប្រជុំបានឯកភាពដាក់ចេញវិធានការបន្ទាន់ចំពោះមុខ ដូចខាងក្រោម÷

**ទី១.** ***ការងារបន្ទាន់ និងជាកិច្ចការអាទិភាព:*** គឺត្រូវស្តារអូរធម្មជាតិទាំង ៥ និងលូ ដែលមានស្រាប់ ដែលសព្វថ្ងៃកំពុងទទួលរងការរំលោភយកចំណីអូរ និងប្រឡាយ ដើម្បីបើកមុខទឹកហូរ និងដោះស្រាយជំនន់ទឹកភ្លៀង ។ ការអនុវត្តកិច្ចការនេះ, ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវមានភាពម៉ឺងម៉ាត់ និងដាក់ឱសានវាទច្បាស់លាស់ ដើម្បីឱ្យម្ចាស់សំណង់អគារ លំនៅដ្ឋានដែលសង់រំលោភលើលូ ប្រឡាយ/អូរធម្មជាតិ ត្រូវរុះរើចេញជាដាច់ខាត ។ ចំពោះសំណង់អគារធំៗ ម្ចាស់សំណង់ត្រូវរៀបចំជីកប្រឡាយវាង/លូបង្ហូរទឹកវាង ដោយរៀបចំជាសំណង់បេតុងស្របតាមស្តង់ដារសំណង់ ។

**ទី២.** ***បង្កើនល្បឿនការស្តារ និងជួសជុលកំណាត់ផ្លូវទាំង ២២ ខ្សែដែលមិនទាន់បានបញ្ចប់:*** ក្រុមការងារដែលទទួលបន្ទុកសិក្សាពីតម្រូវការជួសជុលនៃកំណាត់ផ្លូវទាំងនេះកន្លងមក ត្រូវធ្វើការសិក្សា និងវាយតម្លៃឡើងវិញពីទំហំនៃការជួលជុល ព្រោះថា ស្ថានភាពមានការប្រែប្រួលខ្លាំងនាពេលថ្មីៗនេះ ដែលបង្កដោយជំនន់ទឹកភ្លៀង ការដឹកលើសទម្ងន់ និងការបំពានចំណីផ្លូវ ជាដើម ក៏ដូចជាធ្វើការសិក្សាលើលទ្ធភាពក្នុងការពង្រីក និងកែលម្អផ្លូវវាងក្រុង ដើម្បីសម្រាលបន្ទុកចរាចរលើផ្លូវធំៗមួយចំនួន រាប់ទាំងកំណាត់ផ្លូវជាតិលេខ ៤ ផងដែរ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចសារជាថ្មី ។

**ទី៣.** ***វិធានការរយៈពេលវែង:*** ការកសាងស្ថានីចម្រោះទឹកកខ្វក់ និងការពង្រីកប្រព័ន្ធលូ និងតម្រូវការហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀត នឹងដាក់បញ្ចូលក្នុងការសិក្សាផែនការមេ ដែលគ្រប់ជ្រុងជ្រោយដោយ រាប់ទាំងការគិតគូរពីប្រភពនៃហិរញ្ញប្បទាន តាមគោលការណ៍ “**យកស្លឹកត្នោតខ្ចប់ស្ករត្នោត**” ដែលជាអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដោយយកចំណូលពីការធ្វើឯកជនូបនីយកម្មអចលនទ្រព្យរបស់ខេត្តព្រះសីហនុ ដើម្បីការកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តវិញ សំដៅបង្កើនប្រសិទ្ធភាព និងចីរភាពនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តព្រះសីហនុ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំ បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ដល់ថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលបានចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា រកដំណោះស្រាយ និងផ្តល់ជាធាតុចូលក្នុងផែនការមេនៃការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានបទដ្ឋានបច្ចេកទេសត្រឹមត្រូវ និងបានស្នើឱ្យគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធបន្តចូលរួមផ្តល់កិច្ចសហការប្រកបដោយស្មារតីទទួលខុសត្រូវ និងយោគយល់ខ្ពស់ ។